# ១៧ មេសា ជាថ្ងៃអ្វី ?



៤០ឆ្នាំ កន្លងមក ថ្ងៃទី ១៧ មេសា នៅតែមានអនុភាពក្នុងអារម្មណ៍ខ្មែរជានិច្ច ព្រោះជាទិវានៃប្រជាជាតិខ្មែរ រំលឹកដល់វិញ្ញាណក្ខន្ធ នៃជនខ្មែររងគ្រោះ ពីសំណាក់ របបខ្មែរក្រហម ដែលបានប្រព្រឹត្តអំពើ **ប្រជាករហឹង្សា**[1] មកលើប្រជាជនខ្មែរ ក្នុងរយៈឆ្នាំ ១៩៧៥-១៩៧៨ នាំឲជនខ្មែរបាត់បង់ជីវិតជាង២ លាននាក់ គឺថា ចំនួន ១/៤ នៃ ប្រជាពលរដ្ឋខ្មែរ ។

នាបច្ចុប្បន្ននេះ យើងសង្កេតឃើញ មានខ្មែរយើងខ្លះ ប៉ុនប៉ង លាង បទឧក្រិដ្ឋ ប្រឆាំងនឹងមនុស្សជាតិ របស់ ប៉ុល ពត ពីសតិខ្មែរ តាមសំដីស្នេហាជាតិ គួរឲសង្វេង ថា ប៉ុល ពត ជាអ្នកតស៊ូប្រឆាំងយួន លើសមរភូមិ យោធា, នយោបាយ, មនោគមវិជ្ជា គ្រប់ពេលវេលា ដើម្បី ឯករាជ្យប្រជាជាតិខ្មែរ។ ការសម្លាប់រង្គាល នៅស្រុកខ្មែរ ជំនាន់ កម្ពុជាប្រជាធិបតេយ្យ ឬ ខ្មែរក្រហម ជា ស្នាដៃយួនសុទ្ធសាធ ដែលមានភ្នាក់ងាររបស់វា បង្កប់ខ្លួនក្នុងជួរ ថ្នាក់អ្នកដឹកនាំបក្ស ញុះញង់ឲខ្មែរឈ្លោះគ្នា ដណ្ដើមអំណាចគ្នា នាំហុចប្រយោជន៏ឲយួន។ ពួកគាត់បន្ថែមដោយមានជំនឿជាក់ច្បាស់ក្នុងចិត្តថា ខ្មែរពុំអាចសម្លាប់ខ្មែរបាននោះឡើយ (Sic)។

សំដីនេះ ជា **ការគិតមមៃ**[2] ព្រោះស្អប់ ហើយ រង្គាលចិត្តនឹងយួន ដែលជាអ្នកឈ្លានពានកម្ពុជា ជានិច្ចកាល យកមកដាក់ជានគរចំណុះវាបាន ដែលគួរមិនអាចជឿបាន ក្នុងសតវត្សទី២១ នេះ។ តែសំដីបែបនេះ វាមិនអាចនាំមក នូវការចាំដោយសង្ឃឹមថា ប្រជាជាតិខ្មែរ អាចនឹងបំបាត់ មហិច្ឆិតារាប់ពាន់ឆ្នាំរបស់យួនបាននោះឡើយ ព្រោះប្រើសេចក្ដីសំអាង គ្មានសីលធម៌ និង ឥតសមហេតុផល នាំឲអ្នកស្ដាប់សាមញ្ញ យល់ច្រឡំ រវាង **«ហេតុ» នឹង «ផល»**[3]។ ឧបមាថា ប៉ុល ពត សម្លាប់ខ្មែរ (ជាផល) ព្រោះមានយួនជារនុកក្នុង (ជាហេតុ)។ គេអាចសួរបានថា តើហេតុនេះ មានដើមកំណើតពីអ្វី ? គេអាចឆ្លើយបានថា យួនជារនុកក្នុង (ជាផល) ដោយសារ ប៉ុល ពត ត្រូវការយួន (ជាហេតុ)។ ឆ្លើយទៅ ឆ្លើយមក នេះ នាំឲខ្មែរយើងរកការពិតមិនឃើញ ជួនកាលទុក ប៉ុល ពត ជាអ្នកស្នេហាជាតិ ជួនកាលជា ឃាតករ។ យ៉ាងណាម៉េច ក្នុងរឿង អំពើប្រល័យពូជសាសន៏ នេះ វាមានធាតុសាមញ្ញ និង ភាពជាក់ស្ដែង ស្រួលយល់បំផុត គឺ **ភាពល្ងង់ខ្លៅ និង គ្មានសីលធម៌**[4] របស់ថ្នាក់ដឹកនាំ បក្សកុម្មុយនិស្តខ្មែរ។ ទោះបីក្នុងជួរ អង្គការលើ ពួកខ្មែរក្រហម មាន អ្នកមានសញ្ញាប័ត្រជាន់ខ្ពស់ជាច្រើន តែពួកបញ្ញវន្តទាំងនេះ មានចំណេះវិជ្ជាក្នុងសៀវភៅ តែគ្មានប្រាជ្ញាស្រួច យកការចេះដឹងខ្លួន ធ្វើវិភាគលើមនោគមវិជ្ជាកុម្មុយនិស្ត ដែលខ្លួនទទួលយក ជាទ្រឹស្ដីបដិវត្តន៏ ដើម្បីរិះរកដំណោះស្រាយ សម្របជាមួយនឹង បរិបទ

[1] ប្រជាករហឹង្សា= Violence de masse។
[2] ការគិតមមៃ= Obsession។
[3] ហេតុ នឹង ផល= Cause et effet។
[4] ភាពល្ងង់ខ្លៅ និង គ្មានសីលធម៌= Ignorance et vacuité។

**និពន្ធដោយ ឧប សៅ សង្ហា**
**ថ្ងៃទី ១៤ មេសា ឆ្នាំ ២០១៥**

ខ្មែរ។ កង្វះ នេះ នាំឲបដិវត្តន៍ខ្មែរក្រហម ក្លាយជា អំពើឃាតកម្មរង្គាល សម្លាប់ជនជាតិខ្មែរ ជាង ២លាននាក់ ដោយចេតនា។ ភាពល្ងង់ខ្លៅ និង គ្មានសីលធម៌ នេះឯង ជាហេតុ ឯចំណែក ផលវិញ គឺ រណ្ដៅរួមខ្មោចខ្មែររាប់រយនាក់ មាននៅពាសពេញនគរ ដែលយោធាខ្មែរក្រហមយក ទៅកប់នៅពេល**រត្តិកាល**[5]។ ហេតុ និង ផល នេះឯង ដែលនាំឲប្រជាជាតិខ្មែរ រហិតរហៃ រហូត មក ដែលនាំឲយួនផ្លៀតឱកាស យកកម្ពុជា ដាក់ជានគរចំណុះ ជាទឹកដី **សុង្កាករ**[6] សង្គ្រាម សំរាប់ចិញ្ចឹមជនជាតិយួនរាប់លាននាក់ ចូលមករស់នៅក្នុងស្រុកខ្មែរ។

ថ្ងៃទី ១៧ មេសា ជា វេវចនសព្ទនឹងពាក្យ **និរទេសមហាជន**[7], **អភិសូន្យនៃគ្រប់រូបីបូរី**[8], **និស្ថាបនកម្មនៃលទ្ធវប្បធម៌**[9], ***រំលាយដាច់អហង្ការនូវអ្វីជាខ្មែរ***[10], **ប្រព្រឹត្តអំពើប្រល័យពូជសាសន៍**[11] ក្នុងនាមបដិវត្តន៍ ដែលជា**តម្រាប់**[12] នៃបដិវត្តន៍ ចិន ជាពិសេស ក្នុងសម័យ មហាបដិវត្តន៍វប្បធម៌។ លោក Mao Zedong និយាយថា៖ «*ក្រោយពីបានកំទេចខ្មាំងប្រដាប់អាវុធរួច ហើយ វានៅមានខ្មាំងមិនប្រដាប់អាវុធមួយទៀត ដែលវានឹងអាចវាយប្រហារយើង លុះដល់ក្ស័យជីវិតបាន បើយើងមើលស្រាល នូវ កម្លាំងរបស់វា។ ដូច្នេះបើយើងមិនគិត និង មិនយល់ អំពីខ្មាំងបែបនេះ គឺយើងច្បាស់ជានឹងប្រព្រឹត្ត នូវកំហុសមួយយ៉ាងធំជាពុំខាន*»។ ថ្ងៃទី ១៧ មេសា បើងយកសំដី Mao ជាយោង គឺ អង្គការលើខ្មែរក្រហម បន្តសង្គ្រាមយោធាប្រឆាំងនឹង ប្រជាជនខ្មែរ ព្រោះទុកគាត់ជាសត្រូវគំនិត ដូច្នេះ ត្រូវតែសម្លាប់រង្គាល ជនសង្ស័យទាំងឡាយ ជាវិធានការសំរាប់បង្ការ ដើម្បីការពារបដិវត្តន៍។ តម្រាប់ទាំងងងឹតងងល់បែបនេះជាសញ្ញានូវ ភាពល្ងង់ខ្លៅ និង គ្មានសីលធម៌ របស់អ្នកដឹកនាំ បក្សកុម្មុយនិស្តខ្មែរ។

គេដឹងថា តម្រាប់ មានបីរបៀប៖ ១. ធ្វើតាមទាំងស្រុងឥតចាំបាច់ពិចារណា រកហេតុផល ; ២. ធ្វើតាម ដោយប្រើបញ្ញា ធ្វើវិភាគដើម្បីឲស្គាល់គ្រប់ចំណុចល្អ ចំណុចអាក្រក់ នៃគំរូដើម្បីកែប្រែឲសមស្របនឹង បរិបទ ; ៣. ការលាយគ្នា រវាង របៀបទី១ ជាមួយ របៀបទី២ ក្នុងគោលបំណងរក្សាមូលដ្ឋានដើម ក្នុងការអនុវត្តន៍ នៃគំនិតថ្មី។ ក្នុងរបៀបបីយ៉ាងនេះ គេទុករបៀបទី២ ជារបៀបល្អជាងគេ ព្រោះទុកបញ្ញា ជាពន្លឺ សំរាប់បំភ្លឺ ផ្លូវ និងជា ត្រីវិស័យ សំរាប់សំគាល់ទិស នៃគោលដៅ។ របៀបទី១ ជា **ទំនញ់**[13] នូវការប្រឌិត ដែលនាំឲគំរូ យកមកធ្វើតម្រាប់ វាខុសសម័យ។ របៀបទី៣ អាចឲផល ល្អ ឬ អាក្រក់ ទៅតាមធម្មជាតិនៃគំនិតថ្មី ដែលយកវាមកលាយជាមួយគំរូ។ បើគំនិតថ្មី ជាគំនិតលោភា គ្មានបញ្ញា គឺច្បាស់ជាបង្កើតបញ្ហា ច្រើនជាងការរកដំណោះស្រាយ។

ត្រូវដឹងថា ជីវិត គ្មានបញ្ញា គឺមិនមែនជាជីវិត នៃមនុស្សលោកនោះឡើយ ហើយ ស្លាប់ព្រោះតែល្ងង់ គឺទុកជាមរណៈភាព**អធម**[14]។ វាដូចនឹង ថ្ងៃទី ១៧ មេសា ជាការចាប់ផ្ដើម នៃដំណើរទៅ

[5] រត្តិកាល= ពេលយប់ ; au moment de la nuit។
[6] សុង្កាករ= ពន្ធអាករ ; Tribut។
[7] និរទេសមហាជន= Déportation massive។
[8] អភិសូន្យនៃគ្រប់រូបីបុរី= Anéantissement de toute forme de cité។
[9] និស្ថាបនកម្មនៃលទ្ធវប្បធម៌= ការបំផ្លាញវប្បធម៌ ; Destruction de tout acquis culturel។
[10] រំលាយដាច់អហង្ការនូវអ្វីដែលជាខ្មែរ=Dékhmérisation systématique។
[11] ប្រព្រឹត្តអំពើប្រល័យពូជសាសន៍= Génocide។
[12] តម្រាប់= Imitation។
[13] ទំនញ់= Blocage។
[14] អធម= Misérable។

រក មរណៈភាពអធម នៃបក្សកុម្មុយនិស្តខ្មែរ ដែលអូសទាញប្រជាជាតិខ្មែរឲស្លាប់ជាមួយខ្លួន ព្រោះខ្លួនជាបក្សល្ងង់ខ្លៅ ដឹកនាំបដិវត្តន៍ ក្នុង**អណ្តែតរំពោ**[15]។

**និគ្រោះ**[16]នៅកម្ពុជា (១៩៧៥-១៩៧៨) ជារូបសំណាកនៃនិគ្រោះនៅប្រទេសចិនកុម្មុយនិស្ត។ និគ្រោះ នេះ មានចែងច្បាស់ក្នុងទ្រឹស្តីបក្សកុម្មុយនិស្តចិនគឺ៖ សម្លាប់រង្គាលជនសង្ស័យ ដែលបក្សមានការសង្ស័យថាជាខ្មាំងគំនិត។ តាមការកត់ចំណាំ របស់ Hoang Van Hoan[17], អតិត កម្មាភិបាល វៀតមិុញ រត់ចូល ចិនកុម្មុយនិស្ត, បរិហារថា ចាប់ពីឆ្នាំ១៩៥០ រហូតដល់កិច្ចព្រមព្រៀងនៅទីក្រុង Genève(១៩៥៤) មានជនចិនកុម្មុយនិស្តជាច្រើន ចូលមកក្នុងស្រុកយួន ដើម្បីធ្វើជាទីព្រឹក្សាពួកវៀតមិុញ ហើយក្នុង រយៈឆ្នាំ ១៩៦៥ ដល់ ១៩៧០ មាន ទាហ៊ានជាង ចិនរាប់ពាន់នាក់ ចូលមកជំនួសកិច្ចការ របស់ទាហ៊ានជាងយួន ចេញទៅច្បាំងនៅវៀតណាមខាងត្បូង។ ខុសពីខ្មែរក្រហម ពួកយួនក្រហម គេយករបៀបទី៣ មកអនុវត្តន៍ក្នុងបដិវត្តន៍ គឺ **ការលាយជារបៀប** រវាង គំរូបុព្វបុរសយួន មានឈ្មោះថា «ដំណើរទៅទិសខាងត្បូងនិង ខាងលិច នៃជនជាតិយួន ដើម្បីបង្រិច ទឹកដីសំរាប់ចិញ្ចឹមជីវិត» ជាមួយគំនិតថ្មី គឺយកលទ្ធិកុម្មុយនិស្ត ជាមធ្យោបាយ សំរាប់សមិទ្ធិ នូវមហិច្ឆិតា ជាសហស្សវត្សរ៍។ ការលាយជារបៀបនេះ មានគោលដៅពីរដ៏សំខាន់៖ ឯកភាពជាស្នូល នៃវៀតណាម (តុងកឹង, អាណាម និង កូសាំងស៊ីន ឬ កម្ពុជាក្រោម) និង ឯកភាពជាតម្រូវការ នៃមហាវៀតណាម ឬ ឥណ្ឌូចិន (វៀតណាម,ខ្មែរ,លាវ)៖ ទី១ ជាឫសកែវ ទី២ ជាមែក បង្កើតផលា សំរាប់ចិញ្ចឹមជីវិតប្រជាជនយួន។ តែក្នុងការប្រព្រឹត្តរបៀបទី៣ ដោយយក ទ្រឹស្តីកុម្មុយនិស្តជាគំនិតថ្មី ដែលជាគំនិតមានធាតុហឹង្សា នាំឲប្រជាជនយួនស្លាប់ជាច្រើន ហើយ នាំគ្នា ចំណាកស្រុក ឲចាកផុតពី និគ្រោះនៃរបបកុម្មុយនិស្ត។

រីឯនៅស្រុកខ្មែរវិញ (១៩៧៥-១៩៧៩) ទីព្រឹក្សាចិនជាច្រើន ចូលមកជួយដឹកនាំបដិវត្តន៍ «មហាលោតផ្លោះ» បក្សកុម្មុយនិស្តខ្មែរ ដោយយកការពិសោធ មាននៅស្រុកចិនមកធ្វើជាគំរូ។ គេដឹងថា គម្រោង នៃ មហាលោតផ្លោះ ធ្វើនៅស្រុកចិន (១៩៥៩-១៩៦១) នាំបង្កើត ទុរ្ភិក្ស ស្លាប់មនុស្សរាប់លាននាក់។ ក្នុងគម្រោងនេះ បក្សកុម្មុយនិស្តខ្មែរ យកមកអនុវត្តន៍ ដោយប្រើកម្លាំងប្រជាជន ដូចសត្វពាហនៈ បន្តការតស៊ូវណ្ណៈ កាច់បំបាក់នូវអ្វីជាខ្មែរ តែយកប្រសាទអង្គរវត្ត ជានិមិត្តសញ្ញា នៃជាតិខ្មែរ មកធ្វើជាសញ្ញា នៃអំណាចផ្តាច់ការ របស់ខ្លួន ដូចអំណាចក្នុងសម័យ រាជានិយម និយមទេវរាជ្យ តែ ទេវរាជ្យថ្មី របស់ពួកខ្មែរក្រហម គឺ **ទិដ្ឋិ**[18] នៃប្រព័ន្ធកុម្មុយនិស្ត។ ខ្មែរក្រហម យកចិនជា**គំរូខ្មោះ**[19] ធ្វើតាម បែប របៀបទី១ គឺជា ការចម្លងបិទភ្ជាប់ ដែលនាំឲបដិវត្តន៍ខ្មែរក្រហម ជាប់លេខរៀងទី១ ក្នុងភិភពលោក និង ក្នុងប្រវត្តិសាស្រ្តនៃមនុស្សជាតិ ព្រោះជាបដិវត្តន៍ សម្លាប់រង្គាលប្រជាជនស្លូតត្រង់ ច្រើនជាងគេបង្អស់ យោងតាមសមាមាត្រ នៃចំនួនប្រជាពលរដ្ឋ នឹងចំនួនជនរងគ្រោះ។ តម្រាប់ នៃពួកខ្មែរក្រហមតាមបដិវត្តន៍ចិន ជាស្នាដៃ ប៉ុល ពត ដែលមាន សីហនុ ជា**សំចោរ**[20]។ បុគ្គលពីររូបនេះ មានធម្មជាតិជាមនុស្សមានគំនិត វរើរវាយ មានចរិត យ៉ាងសាហាវ គិតតាំងខ្លួនជាមនុស្សឆ្នើមក្នុងលោក ; មួយជាបងទី១ នៃបដិវត្តន៍ មួយទៀត ជាបិតាជាតិ រួមដៃគ្នាធ្វើឃាតខ្មែររួម

15 អណ្តែតរំពោ= ដំណើរគ្មានគោលដៅប្រាកដ ; Voyage sans but précis។
16 និគ្រោះ= Répression។
17 Hoang Van Hoan, Une goutte d’eau dans le grand océan – souvenirs révolutionnaires, Paris 1989។
18 ទិដ្ឋិ= Dogme។
19 គំរូខ្មោះ= Modèle brut។
20 សំចោរ= ចូលដៃ ; Complice។

ជាតិ ដែលជាញាតិរួមឈាមនឹងខ្លួន ; មួយក្នុងនាម បដិវត្តន៍មហាលោតផ្លោះ, មួយទៀតក្នុងនាម ការសងសឹក**រឡប់**[21]។

យើងអាចសួរជាសំណួរថា ការសម្លាប់រង្គាល តើជា ប្រពៃណី នៃប្រព័ន្ធដឹកនាំជាតិ របស់អ្នកដឹកនាំខ្មែរឬ ?

មកដល់ចុងសតវត្សទី១៩ ចំនួនប្រជាពលរដ្ឋខ្មែរ បូករួមទាំង កម្ពុជាកណ្ដាល និងកម្ពុជាក្រោម មានត្រឹមតែ ៨០០.០០០ នាក់។ ចំនួននេះ វាផ្ទុយគ្នា នឹងទំហំទឹកដី និង **កិរ្តិ៍**[22] ជាមហានគរ ហើយ បញ្ជាក់ដែរ នូវឱនភាពជាតិខ្មែរ មានហេតុជាច្រើនៈ មកពីសង្គ្រាមស៊ីវិល ? សង្គ្រាមការពារជាតិ ? មកពីការបាត់បង់ទឹកដី ដែលប្រទេសជិតខាង គេយកទៅបញ្ចូលក្នុងនគរគេ ? មកពីប្រព័ន្ធដឹកនាំជាហឹង្សា យកការសម្លាប់រង្គាលប្រជាជន ដើម្បី ការពារអំណាច? ហេតុទាំងឡាយនេះសុទ្ធតែជាចំណែក នាំឲជាតិខ្មែរធ្លាក់ក្នុងឱនភាព។ តែហេតុដែល ជាពិស មរណៈបណ្ដាល ឲស្លាប់ជាតិ គឺ ការសម្លាប់ប្រជាជនដើម្បីការពារអំណាច នាំហុចឱកាសឲគ្រប់សត្រូវរបស់ជាតិឆ្លៀតទាញយកចំណេញ មានស្នាមនៅក្នុងប្រវតិសាស្ត្រខ្មែរៈ ការរំលំមហានគរ, ការរលាយបន្ទាយលង្វែក, ការហិនហោច នៃអនុភាពនគរ, ការប្រាសចាកសិទ្ធិ និង សេចក្ដីខ្មាស់របស់ ជាតិសាសន៏ខ្មែរ។ សារព័ន នូវ ភយន្តរាយ ដែលបានរៀបរាប់ខាងលើនេះ ត្រូវបាន សីហនុ និង ប៉ុលពត បង្កើតជាថ្មី នៅ ថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ ដែលជាថ្ងៃ ដែលខ្មែរ ទាំង ស៊ីវិល និង យោធា នាំគ្នាលើកទង់ស ទទួលអបអរសាទរ ដ៏ស្មោះ ព្រោះមានជំនឿថា មាន ការបញ្ចប់សង្គ្រាម រវាងខ្មែរ នឹងខ្មែរ។ សួរថា នេះឬ ជា ការរំដោះ ដោយខ្លាំងពូកែ និង ជា**មហោឡារ**[23] ខ្មែររំដោះ ? ព្រោះ ៣ឆ្នាំ ៩ខែ ក្រោយមក ស្រុកខ្មែរត្រូវបានកងទ៏ពយួនវាយរំលាយ របបប្រល័យពូជសាសន៏ខ្មែរក្រហម ហើយចូលកាន់កាប់ ស្រុកខ្មែរបានយ៉ាងងាយបំផុតដាក់ជាប្រទេសចំណុំ។ ខ្មោច Phan Van Dong, កាលនោះជារដ្ឋមន្ត្រីទី១ វៀតណាម, ថ្លែងថាស្ថានការណ៏នៅស្រុកខ្មែរពុំអាចថយក្រោយវិញបាននោះឡើយ។ សំដីនេះមានន័យច្បាស់លាស់ថា យួនចូលស្រុកខ្មែរបានហើយមិនសុខចិត្ត ចេញវិញជាដាច់ខាត។ ការមិនថយក្រោយនេះ ក្លាយជាការពិតមួយ សំរាប់ជនជាតិខ្មែរ ព្រោះ ខ្មោចសីហនុ បានធ្វើគ្រប់បែបយ៉ាងដើម្បីឲសំដីយួននេះ មានអានុភាព ជានិច្ច នៅក្នុងស្រុកខ្មែរ រហូតមក។

ប្រវតិសាស្ត្រ ស្រុកខ្មែរ ពិតជាកត់ទុកថា ថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ ជាអំពើ ក្បត់ជាតិ របស់សីហនុ, ប៉ុល ពត និង អ្នកដឹកនាំ នៃ របបខ្មែរក្រហម ព្រោះជនទាំងនេះ នាំគ្នាផ្ទៃ ឆន្ទៈនៃសន្តិភាព របស់ប្រជាជនខ្មែរ ឲស្រុកខ្មែរក្លាយជាព្រៃខ្មោច។ អំពើក្បត់ជាតិ របស់ សីហនុ នេះ នៅមានបន្ត មកដល់ ឆ្នាំ ១៩៩៣ ព្រោះទ្រង់ ធ្វើសហការណ៏ ជិតស្និត ជាមួយ គណបក្សប្រជាជន ដែលជាបក្ស រណបយួនកុម្មុយនិស្ត ដើម្បីរក្សាអំណាចផ្ដាច់ការ និង អាណានិគមយួន នៅកម្ពុជា។ មកដល់ឆ្នាំ ២០១៤ នៅថ្ងៃទី ២២ កក្កដា **សហសន្តតិជន**[24] នៃនយោបាយសីហនុនិយម គឺ សម រង្ស៊ី និង កែម សុខា បន្តអំពើក្បត់ជាតិ ពីព្រះសព វរៈក្សត្រ របស់គេ គឺថា នាំគ្នាចូលទៅបំរើនយោបាយ អនានិគមយួន នៅក្នុងរដ្ឋសភា ឥតស្របច្បាប់ របស់ ហ៊ុន សែន។ ពីវប្បធម៏ចរចារ មកដល់ វប្បធម៏សន្ទនា ដែល សម រង្ស៊ី ប្រឌិតឡើង ថា វប្បធម៏នេះ អាច រក្សា

---

[21] រឡប់= ឆ្កួតលីលា= Dingue, excité។
[22] កិរ្តិ៍= Réputation។
[23] មហោឡារ= Sublime។
[24] សហសន្តតិជន= Cohéritiers។

## ១៧ មេសា ជាថ្ងៃអ្វី ?

សន្តិភាពនៅស្រុកខ្មែរ និង ការដោះលែងឲនៅក្រៅឃុំ នៃសកម្មជនតវ៉ាដីធ្លី, សមាជិកគណបក្សសង្គ្រោះជាតិ, ព្រះសង្ឃ និង ការព្យួរជាបណ្តោះអាសន្ន នៃការចោទប្រកាន់ពីតុលាកា ហ៊ុន សែន ដល់ កែម សុខា, តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ មួយចំនួន និង សម រង្ស៊ី ខ្លួនឯង ពីបទដឹកនាំប្រជាជន ឲបេះបោរប្រឆាំងនឹង ហ៊ុន សែន។ តែ សម រង្ស៊ី ឥតបាននិយាយឲប្រជាជាតិដឹងថា គណបក្សសង្គ្រោះជាតិបានធ្វើសម្បាទានអ្វីខ្លះដល់យួនដែលជាចៅហ្វាយហ៊ុនសែន សំរាប់ប្រយោជន៏នយោបាយ និង អត្តប្រយោជន៏៖ បញ្ហ័យនេះ គឺគ្មានអ្វីក្រៅពី ការបាត់បង់ឯករាជ្យជាតិ និង បូរណភាពទឹកដីខ្មែរ។ ការសន្ទនា ខ្សឹបៗ រវាង សម រង្ស៊ី ជាមួយនឹងហ៊ុនសែន វាគ្មានមូលដ្ឋានច្បាប់ សំរាប់ធានាអ្វីនោះឡើយ វាគ្រាន់តែជាមធ្យោបាយ របស់ហ៊ុនសែន សំរាប់យកមកបំរើប្រយោជន៏យួន ព្រោះប្រយោជន៏នេះ វាជាអាយុជីវិត របស់ខ្លួននិងគ្រួសារ។ ទង្វើអ្វីដែល សម រង្ស៊ី កំពុងធ្វើ គឺធ្វើនៅក្នុងគតិ ថ្ងៃទី ១៧ មេសា នេះឯង គឺថានាំប្រជាជាតិខ្មែរ ដើរទៅរករណ្តៅមរណៈ។ ពរដែល សម រង្ស៊ី ជូនដល់ប្រជាជនខ្មែរ នៅក្នុងទិវាចូលឆ្នាំខ្មែរថ្មីនេះ គឺជាការជូនពរ របស់មនុស្សខូច លាក់ពុត មានរូបកាយជាមនុស្ស តែមានសភាវគតិ ជាឆ្កែ បំរើចោរ, ដូច្នេះពរ នេះ ជា ពរ ដ៏ចង្រៃបំផុត សំរាប់ ប្រជាជាតិខ្មែរ។

រួមសេចក្តីមក យើងជាខ្មែរ អាចសន្និដ្ឋានបានថា ស្រុកខ្មែរ ក្លាយជាស្រុកខ្ញុំយួន គឺជា ផលវិបាក នៃថ្ងៃ ទី១៧ មេសា, ហេតុនេះឯងបាន ជាទិវា ១៧ មេសា នៅតែផ្តិតជាប់ក្នុងសតិ ខ្មែររហូតមក។ សព្វថ្ងៃនេះទៀត ខ្មែរយើងទុក ថ្ងៃ ទី១៧ មេសា ជា វេរចនសព្ទនឹងឈ្មោះអាស្រូវ ដូចជា សីហនុ, ប៉ុល ពត, ហ៊ុនសែន, សម រង្ស៊ី នឹង កែម សុខា ដែលជាជនក្បត់ជាតិ។៙